Collaborative Curriculum
and Assessment Framework
for Languages

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | |

Write your **student number** in the boxes above. **Letter**

# 2025 Khmer Examination

## Continuers Level

**Date:** Thursday 16 October 2025, 2 pm Australian Eastern Daylight Time

- Reading time: **10 minutes**
- Working time: **2 hours**
- Total marks: **65**

### Approved materials

- Black or blue pens
- Monolingual and/or bilingual printed dictionaries

### Materials supplied

- Question-and-answer booklet

### Instructions

- You may consult your dictionaries during reading time and also during the examination.
- Write all your answers in the spaces provided in this booklet. The spaces provided give you an idea of how much you should write.
- You **must not** write during reading time.

### Contents

page

**Section 1** – Responding to texts

- **Question 1** (7 marks) ........ 2
- **Question 2** (8 marks) ........ 4
- **Question 3** (15 marks) ........ 6

**Section 2** – Creating texts

- **Question 4** (15 marks) ........ 10
- **Questions 5 and 6** (20 marks) ........ 15

© SACE Board of South Australia 2025

SACE BOARD SOUTH AUSTRALIA

Government of South Australia

## **Section 1** – Responding to texts (30 marks)

Allow approximately 50 minutes for Section 1.

**Question 1** – Listening in Khmer and responding in English (7 marks)

### Instructions

- Text 1 will be played twice. There will be a short break between each playing.
- You may write notes at any time in the space provided. These notes will not be assessed.
- Listen carefully to the text and then answer the questions in **ENGLISH**.
- Responses in languages other than English will not be assessed.
- All responses **must** be based on the text.

---

**Your responses will be assessed on how well you:**

- analyse general and specific relevant information, ideas, opinions, perspectives and/or aspects of texts to convey meaning.

---

**Question 1** **Marks**

**a.** How does the speaker support their use of the phrase ‘It is a potential environment disaster’? **5**

Write your notes here. Notes will **not** be assessed.

**Marks**

Write your notes here. Notes will **not** be assessed.

**b.** Why would this advertisement appeal to people who like fashion but are also environmentally minded? **2**

Support your answer with *two* examples from the text.

## **Question 2** – Listening and responding in Khmer (8 marks)

### Instructions

- Text 2 will be played twice. There will be a short break between each playing.
- You may write notes at any time in the space provided. These notes will not be assessed.
- Listen carefully to the text and then answer the questions in **KHMER**.
- Responses in languages other than Khmer will not be assessed.
- All responses **must** be based on the text.

---

**Your responses will be assessed on how well you:**

- analyse general and specific relevant information, ideas, opinions and/or perspectives to convey meaning.

---

**Question 2** **Marks**

**a.** How well do the speakers know each other? **3**

Support your answer with evidence from the text.

តើអ្នកនិយាយទាំងពីរស្គាល់គ្នាច្បាស់ប៉ុណ្ណា? ចូរគាំទ្រចំឡើយរបស់អ្នកដោយស្រង់ភស្តុតាងពីអត្ថបទ។

Write your notes here. Notes will **not** be assessed.

**Marks**

Write your notes here. Notes will **not** be assessed.

**b.** Compare and contrast Sokha and Kunthea's thoughts about taking a gap year. **5**

ប្រៀបធៀបគំនិតដូចគ្នា និងខុសគ្នារបស់សុខា និងគន្ធាអំពីការឈប់សិក្សាមួយរយៈ។

**Question 3** – Reading and listening in Khmer, responding in English (15 marks)

**Instructions**

- This question consists of a reading text, Text 3A, and a related listening text, Text 3B.
- You have 5 minutes to read Text 3A. At the end of the 5 minutes, Text 3B will be played. The text will be played twice. There will be a short break between each playing.
- You may write notes at any time in the space provided. These notes will not be assessed.
- Answer the questions in **ENGLISH**.
- Responses in languages other than English will not be assessed.
- All responses **must** be based on the text(s).

---

**Your responses will be assessed on how well you:**

- analyse general and specific relevant information, ideas, opinions, perspectives and/or aspects of texts to convey meaning
- synthesise relevant information, ideas, opinions and/or perspectives from different texts.

---

### Text 3A

**ការពង្រឹងសមត្ថភាពយុវជនតាមរយៈការបណ្តុះបណ្តាលផ្នែកបដិសណ្ឋារកិច្ច**

អ្នកប្រាកដជាស្គាល់សុធារី ជាចុងភៅដែលមានទេពកោសល្យ និងជាអ្នកជំនួញជោគជ័យម្នាក់ដែលគ្រប់គ្រងភោជនីយដ្ឋានខ្មែរដ៏ល្បីល្បាញនៅប្រទេសចំនួន 3 ប៉ុន្តែតើអ្នកដឹងថានាងបានជួយសង្គមយ៉ាងខ្លាំងដែរឬទេ?

ក្នុងឆ្នាំ 2010 សុធារី បានសម្រេចចិត្តថានាងចង់ប្រើជំនាញរបស់នាងដើម្បីជួយដល់សហគមន៍របស់នាង ដូច្នេះនាងបានបើកមជ្ឈមណ្ឌលបណ្តុះបណ្តាលបដិសណ្ឋារកិច្ចមួយនៅទីក្រុងភ្នំពេញ។ គោលដៅរបស់នាងគឺ ដើម្បីផ្តល់ឱ្យយុវជនដែលមានជីវភាពក្រីក្រនូវចំណេះដឹង បទពិសោធន៍ និង ជំនាញដែលត្រួសត្រាយផ្លូវសម្រាប់អនាគតដ៏ភ្លឺស្វាង និងបង្កើតផលវិជ្ជមានដែលមាននិរន្តរភាព។

សព្វថ្ងៃនេះកម្មវិធីបណ្តុះបណ្តាល 'Taste of Hope Cambodia' បានផ្លាស់ប្តូរជីវិតយុវជនជាង 600នាក់។ សុធារី បានធានាថាកម្មវិធីនេះមិនត្រឹមតែបង្រៀនបច្ចេកទេសចម្អិនអាហារនោះទេ នាងចង់ជួយយុវជនអោយចេះគ្រប់គ្រងជីវិតរបស់ពួកគេតាមរយៈការបង្កើនទំនុកចិត្តខ្លួនឯង ការកសាងជំនាញធ្វើការជាក្រុមដ៏សំខាន់និង មានគោលដៅក្នុងជីវិត។

និស្សិតបញ្ចប់ការសិក្សាពីកម្មវិធីនេះជាទូទៅទទួលបានការងារជាប់លាប់ មានប្រាក់ចំណូលស្ថេរភាព និង កសាងមូលដ្ឋានគ្រឹះសម្រាប់ជីវិតមួយកាន់តែប្រសើរ។ យើងជាញឹកញាប់នៅតែរក្សាទំនាក់ទំនង ផ្តល់ការគាំទ្រនិង ការណែនាំជាបន្តបន្ទាប់ទៅដល់និស្សិតដែលបានបញ្ចប់ការសិក្សាពីកម្មវិធីដើម្បីជួយឱ្យចុងភៅវ័យក្មេងទាំងនេះតែនៅបន្តលូតលាស់នៅក្នុងអាជីពថ្មីរបស់ពួកគេ។

និស្សិតបញ្ចប់ការសិក្សាពីកម្មវិធីដែលធ្វើការក្រៅពីផ្នែកបដិសណ្ឋារកិច្ចបានចូលរួមជួយដល់សហគមន៍របស់ពួកគេវិញដោយប្រើប្រាស់ជំនាញដែលទទួលបានពីកម្មវិធី។
និស្សិតបញ្ចប់ការសិក្សាពីកម្មវិធីដែលកំពុងធ្វើការក្នុងផ្នែកដឹកជញ្ជូនអាហារ ផ្នែកទីផ្សារ និងការលក់ដុំបានបន្តជួយកម្មវិធីតាមរយៈការផ្ដល់សេវាកម្មដែលមានតម្លៃថោក។
វិធីនេះវាមិនត្រឹមតែជួយផ្លាស់ប្ដូរជីវិតមនុស្សម្នាក់ៗប៉ុណ្ណោះទេ វាថែមទាំងជួយសហគមន៍ទាំងមូលផងដែរ។

ខ្ញុំគិតថាអ្នកយល់ស្របថា សុធារីពិតជាបុគ្គលដ៏គំរូម្នាក់។ ការងាររបស់អង្គភាពនាងបានបង្ហាញថា ឱកាស ការខិតខំប្រឹងប្រែង និងក្ដីសង្ឃឹមអាចផ្លាស់ប្ដូរជីវិតបាន។

**Question 3** **Marks**

**Text 3A**

**a.** How does the writer of text 3A use language to engage the audience? **2**

Provide examples from the text to support your answer.

Write your notes here.
Notes will **not** be assessed.

**Question 3** continues on the next page.

**Marks**

Write your notes here. Notes will **not** be assessed.

**b.** What evidence is there that Sotheary has been successful in creating a cycle of positive impact? **3**

**Text 3B**

**c.** Why did Visal say that 'he almost gave up a few times'? **4**

**Texts 3A and 3B**

**Marks**

Write your notes here. Notes will **not** be assessed.

**d.** To what extent is the Taste of Hope Cambodia program achieving its aim of paving the way for a brighter future for disadvantaged youth? **6**

Support your answer with evidence from both texts 3A and 3B.

**End of Section 1**

## **Section 2** – Creating texts (35 marks)

Allow approximately 70 minutes for Section 2.

**Question 4** – Reading and responding in Khmer (15 marks)

### Instructions

- Read Text 4 and write a response of approximately 150 words in **KHMER**.
- Question 4 is phrased in both English and Khmer.
- Responses in languages other than Khmer will not be assessed.

---

**Your response will be assessed on how well you:**

- analyse relevant information, ideas, opinions and/or perspectives from the stimulus text(s)
- respond to the question appropriately for the context, purpose and audience
- use appropriate language structures and vocabulary accurately.

---

### Text 4

**តើអ្នកស្គាល់យុវជនណាម្នាក់ដែលមានចំណាប់ចំណូលចិត្តលើភាសា និងវប្បធម៌ទេ?**

ពានរង្វាន់សម្រាប់ភាសា និងវប្បធម៌ឥឡូវនេះចាប់ផ្តើមហើយ។ ពានរង្វាន់នេះត្រូវបានបង្កើតឡើងដើម្បីទទួលស្គាល់និងលើកកម្ពស់យុវជនដែលបំផុសគំនិតដែលបានបង្ហាញពីភាពជាអ្នកដឹកនាំ និងការប្តេជ្ញាចិត្តក្នុងការលើកកម្ពស់ភាសា និងវប្បធម៌ផ្សេងៗគ្នានៅក្នុងប្រទេសអូស្ត្រាលី។

**លក្ខណៈវិនិច្ឆ័យជ្រើសរើស**

1. មានអាយុក្រោម 24 ឆ្នាំដែលកំពុងបន្តការសិក្សានៅប្រទេសអូស្ត្រាលី
2. មានសមត្ថភាពនិយាយច្រើនជាងមួយភាសា
3. មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការសិក្សា ឬលើកកម្ពស់ភាសា និងវប្បធម៌
4. សមត្ថភាពក្នុងការធ្វើការបានល្អជាមួយមនុស្សមានវប្បធម៌ និងភាសាខុសពីខ្លួន
5. លើកទឹកចិត្ត និងលើកកម្ពស់សារៈសំខាន់នៃការរៀនភាសាផ្សេងទៀត និងគោរពវប្បធម៌ទាំងអស់នៅក្នុងសាលា និងឬសហគមន៍ទូទៅ
6. ចូលរួមយ៉ាងសកម្មក្នុងសហគមន៍ និងឬព្រឹត្តិការណ៍ស្ម័គ្រចិត្តផ្សេងៗ

ដើម្បីតែងតាំងមនុស្សម្នាក់ ចូរបំពេញទម្រង់បែបបទដោយឆ្លើយតបទៅនឹងលក្ខខណ្ឌនៃការជ្រើសរើសទាំងអស់ ព្រមទាំងផ្តល់ព័ត៌មានដែលពាក់ព័ន្ធ ទៅកាន់គណៈកម្មការជ្រើសរើស អ្នកស្រី តាន់ ស៊ីនួន តាមរយៈអ៊ីម៉ែល email sinourn@gmail.com ។

ការតែងតាំងបញ្ចប់នៅថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០២៥។

You may make notes in this space. These notes will **not** be assessed.

**Question 4** continues on the next page.

**Question 4** (15 marks)

You have read this call for nominations and decide to nominate yourself or someone you know for this award. Write an email to the award committee addressing the selection criteria and convincing them that you are the best applicant.

អ្នកបានអានសេចក្តីប្រកាស អំពីការតែងតាំងនេះ ហើយសម្រេចចិត្តតែងតាំងខ្លួនឯង ឬនរណាម្នាក់ដែលអ្នកស្គាល់ សម្រាប់ពានរង្វាន់នេះ។ ចូរសរសេរអ៊ីម៉ែលមួយទៅគណៈកម្មការជ្រើសរើស ដោយឆ្លើយតបទៅនឹងលក្ខខណ្ឌនៃការជ្រើសរើសទាំងអស់ ហើយបញ្ចុះបញ្ចូលគណៈកម្មការថាអ្នក ឬមនុស្សដែលអ្នកតែងតាំងគឺជាបេក្ខជនដ៏សមស្របបំផុតសម្រាប់រង្វាន់នេះ។

You may make notes in this space. These notes will **not** be assessed.

**Questions 5 and 6** – Writing in Khmer (20 marks)

## Instructions

- Question 5 and Question 6 are written in English and Khmer.
- Choose **one** question, either Question 5 **or** Question 6.
- Write a response of approximately 250 words in **KHMER**.
- Responses in languages other than Khmer will not be assessed.

---

**Your response will be assessed on how well you:**

- create text appropriate for the context, purpose and audience
- demonstrate depth of treatment of information, ideas, opinions or perspectives
- sequence information, ideas, opinions or perspectives cohesively
- use a range of appropriate language structures and vocabulary
- use vocabulary and language structures accurately.

---

You may make notes in this space. These notes will **not** be assessed.

**Questions 5 and 6** continue on the next page.

**Question 5** (20 marks)

You decide to cut down on your phone usage to better achieve your academic and personal goals. Write a diary entry reflecting on how this reduction could help you reach these goals. Include specific examples and plans for managing your time more effectively.

អ្នកសម្រេចចិត្តកាត់បន្ថយការប្រើប្រាស់ទូរស័ព្ទ ដើម្បីសម្រេចបានគោលដៅសិក្សានិងគោលបំណងផ្ទាល់ខ្លួនឱ្យប្រសើរជាងមុន។

ចូរសរសេរកំណត់ហេតុប្រចាំថ្ងៃជាភាសាខ្មែរដោយឆ្លុះបញ្ចាំងពីរបៀបដែលការកាត់បន្ថយការប្រើប្រាស់ទូរស័ព្ទ អាចជួយឱ្យអ្នកសម្រេចបាននូវគោលដៅទាំងនេះ។

ចូរលើកឧទាហរណ៍អោយបានជាក់លាក់ និងផែនការសម្រាប់ការគ្រប់គ្រងពេលវេលាឱ្យកាន់តែមានប្រសិទ្ធភាពជាងមុន។

**OR**

**Question 6** (20 marks)

A mysterious photo from a recent school excursion has surfaced. The photo has everyone guessing about its origins and the story behind it. Write a story based on the image below for your Khmer creative writing group.

រូបភាពដ៏គួរឱ្យភ្ញាក់ផ្អើលមួយទទួលបានក្រោយការធ្វើដំណើរទស្សនកិច្ចសិក្សានៅក្រៅសាលាថ្មីៗនេះ។រូបភាពនោះបានធ្វើឱ្យគ្រប់គ្នាទាយអំពីដើមកំណើត និងសាច់រឿងនៅខាងក្រោយរបស់វា។

ចូរសរសេររឿងនិទានមួយជាភាសាខ្មែរផ្អែកទៅលើរូបភាពខាងក្រោមនេះ សម្រាប់ក្រុមសរសេរសាច់រឿងបែបច្នៃប្រឌិតជាភាសាខ្មែររបស់អ្នក។



Source: adapted from © Tithi Luadthong | Shutterstock.com

Select either Question 5 **or** Question 6 by placing a tick (✓) in one of the boxes below.

Question 5 ☐ Question 6 ☐

**End of examination questions**

**Extra space for responses**

Clearly **number** all responses in this space.

© SACE Board of South Australia 2025

KHMER (CONTINUERS) EXAMINATION 2025
SECTION 1 – RESPONDING TO TEXTS

Text 1

សួស្តីអ្នកនិយមម៉ូដទាំងអស់គ្នា!

នៅហាង Eco Style ផ្តល់ជូននូវសម្លៀកបំពាក់ដែលប្រើប្រាស់រួចនិងមានគុណភាពខ្ពស់ ពីព្រោះយើងជឿជាក់ថាភាពទាន់សម័យមិនចាំបាច់ប៉ះពាល់បរិដ្ឋានទេ។។ តើអ្នកដឹងទេថា ឧស្សាហកម្មសម្លៀកបំពាក់ចូលរួមបំភាយឧស្ម័នពុលជាសកលប្រហែល 10%។ វាច្រើន ជាងការបំភាយរួមគ្នារវាងការហោះហើរអន្តរជាតិ និង ការដឹកជញ្ជូនតាមសមុទ្រ។ នេះជា មហន្តរាយបរិដ្ឋានមួយដ៏ធ្ងន់ធ្ងរ។

ការផលិតសម្លៀកបំពាក់ក៏ត្រូវការធនធានធម្មជាតិមានតម្លៃជាច្រើនផងដែរ។

ឧទាហរណ៍ ការផលិតអាវយឺតអំពីកប្បាសមួយអាចប្រើប្រាស់ទឹករហូតទៅដល់2,700 លីត្រ។

លើសពីនេះទៀតការរីកចំរើនយ៉ាងឆាប់រហ័សនៃម៉ូដសំលៀកបំពាក់នាំអោយមានការប្រើប្រាស់ហួសកម្រិត បណ្តាលអោយសម្លៀកបំពាក់រាប់លានតោនត្រូវចោលនៅកន្លែងចាក់សម្រាម ហើយចំណាយពេលជាច្រើនទសវត្សរ៍ដើម្បីរលួយ។

នៅពេលអ្នកទិញទំនិញពីយើង អ្នកមិនត្រឹមតែសន្សំលុយលើសម្លៀកបំពាក់ទាន់សម័យទេ អ្នកក៏កាត់បន្ថយកាកសំណល់ និង សន្សំសំចៃធនធានផងដែរ។

សូមចូលទៅមើលតាមរយៈអនឡាញនៅថ្ងៃនេះ។

រាល់ការទិញទំនិញគឺជាជំហ៊ានមួយទៅកាន់អនាគតមួយដែលមានពណ៌កាន់តែបៃតង។

Text 2

**សុខា:** សួស្តី គន្ធា! ខ្ញុំឈ្មោះសុខា! ជាការល្អណាស់ដែលបានលឺការនិយាយរបស់**គន្ធា**នៅសមាគមខ្មែរថ្ងៃនេះ។

**គន្ធា:** អរគុណសុខា។ តើសុខាជាសិស្សអន្តរជាតិមកពីប្រទេសកម្ពុជាឬ?

**សុខា:** អត់ទេ គ្រួសារខ្ញុំបានមករស់នៅក្នុងប្រទេសអូស្ត្រាលី ជាច្រើនជំនាន់មកហើយ។ ខ្ញុំចាប់អារម្មណ៍ការនិយាយរបស់**គន្ធា**ពីព្រោះខ្ញុំមានគម្រោងចង់សំរាកមួយរយៈមុនពេលចូលមហាវិទ្យាល័យ។ តើគេនិយមទេនៅស្រុកខ្មែរ។

**គន្ធា:** អត់ទេ មិនមានអ្នកចូលចិត្ត ការសម្រាកសិក្សាមួយរយៈទេ។ គ្រួសារខ្ញុំគិតថាវាជាការខ្ជះខ្ជាយពេលវេលា ខ្ញុំគួរតែចាប់ផ្តើមចូលរៀននៅមហាវិទ្យាល័យ។

**សុខា:** វាជាការពិត ប៉ុន្តែខ្ញុំគិតថាការសម្រាកសិក្សាមួយរយៈនឹងជួយឱ្យខ្ញុំស្វែងរកអ្វីដែលខ្ញុំចង់ធ្វើពិតប្រាកដ។ តាមវិធីនេះ ខ្ញុំអាចកាត់បន្ថយឱកាសជ្រើសរើសមុខវិជ្ជាខុសនៅសាកលវិទ្យាល័យ ហើយមិនខ្ជះខ្ជាយពេលវេលានិងលុយកាក់ទេ។

**គន្ធា:** តើសុខាគិតថាវាអាចពិបាកទេនៅពេលត្រឡប់ទៅរៀនវិញបន្ទាប់ពីឈប់សម្រាកមួយឆ្នាំ។

**សុខា:** អាចពិបាក! ប៉ុន្តែខ្ញុំមានគម្រោងធ្វើការស្ម័គ្រចិត្ត ដើរកម្សាន្ត និងទទួលបទពិសោធន៍ជីវិតពិត។ វាអាចជួយឱ្យខ្ញុំរីកចំរើន និងត្រៀមខ្លួនរួចរាល់សម្រាប់ចូលមហាវិទ្យាល័យ។

**គន្ធា:** ចំពោះខ្ញុំ ពេលវេលាមានតម្លៃខ្លាំងណាស់។ ពេលខ្ញុំបញ្ចប់ការសិក្សាបានកាន់តែលឿន ខ្ញុំអាចចាប់ផ្តើមធ្វើការ បានកាន់តែឆាប់ និងអាចជួយគ្រួសារខ្ញុំ។ វាមានសារៈសំខាន់ក្នុងវប្បធម៌ខ្ញុំ។

**សុខា:** ហេតុផលសមស្រប។ ចាប់អារម្មណ៍ទេ! វប្បធម៌កំណត់ការគិតថាតើការសម្រាកសិក្សាមួយរយៈគឺជាការសិក្សាស្វែងយល់ដ៏សំខាន់ឬជាការខាតពេលឥតប្រយោជន៍។

**គន្ធា:** ត្រឹមត្រូវ។ សំណាងល្អជាមួយផែនការនេះសុខា!

Text 3B

**អ្នកសម្ភាសន៍:** សូមស្វាគមន៍មកកាន់កម្មវិធី"ផ្លាស់ប្តូរអនាគត"។
ថ្ងៃនេះមានការចូលរួមពីប្អូន សុខ វិសាលដែលបានបញ្ចប់ការសិក្សាពីកម្មវិធីផ្លាស់ប្តូរជីវិតមួយកាលពីឆ្នាំមុន។
តើប្អូនអាចរៀបរាប់បន្តិចអំពីជីវិតប្អូនមុនចូលកម្មវិធីបានទេ?

**វិសាល:** បាទជំរាបសួរបង។ និយាយត្រង់ទៅ ជីវិតលំបាកណាស់។ ខ្ញុំធំឡើងនៅភ្នំពេញដោយគ្មានផ្ទះពិតប្រាកដ ហើយមិនបានរៀនចប់ទេ។ បន្ទាប់មកអ្នកស្ម័គ្រចិត្តម្នាក់មកពីសាលាTaste of Hope Cambodiaបានលើកទឹកចិត្តខ្ញុំអោយចូលរួមកម្មវិធី។ គាត់ប្រាប់ថាខ្ញុំអាចរៀនជំនាញ និង ទទួលបានការងារមួយ។

**អ្នកសម្ភាសន៍៖** តើកម្មវិធីនោះយ៉ាងម៉េចដែរ?

**វិសាល:** នៅពេលចាប់ផ្តើម ខ្ញុំមិនសូវមានទំនុកចិត្តទេ ខ្ញុំមិនធ្លាប់ធ្វើការនៅក្នុងផ្ទះបាយពីមុនទេ គ្រប់យ៉ាងថ្មីទាំងអស់។ ខ្ញុំបានធ្វើកំហុសជាច្រើន។

**អ្នកសម្ភាសន៍:** តើហេតុអ្វីបានជាប្អូននៅតែបន្ត?

**វិសាល:** បាទការពិត ខ្ញុំស្ទើរតែបោះបង់ពីរបីដង ។ ខ្ញុំពិបាកបន្សុំខ្លួនជាមួយភាពរវល់រៀងរាល់ថ្ងៃណាស់។
ប៉ុន្តែមេចុងភៅមានការអត់ធ្មត់ ហើយពួកគាត់មិនត្រឹមតែបង្រៀនពីរបៀបចម្អិនអាហារទេ ខ្ញុំបានរៀនអំពីវិន័យ ការងារជាក្រុម និងការគោរពខ្លួនឯង។

**អ្នកសម្ភាសន៍:** តើប្អូនកំពុងធ្វើអ្វីឥឡូវនេះ?

**វិសាល:** ខ្ញុំមានមោទនភាពក្នុងការនិយាយថាឥឡូវនេះខ្ញុំជាចុងភៅម្នាក់ដែលមានការងារស្ថេរភាព។

ក្តីសង្ឃឹមមួយដែលគ្រាន់តែជាការស្រម៉ៃឥឡូវបានក្លាយជាការពិត។ ខ្ញុំអាចជួយបងប្អូនខ្ញុំបាន។ កម្មវិធីនេះមិនត្រឹមតែផ្លាស់ប្តូរជីវិតខ្ញុំទេ វាបានជួយសង្គ្រោះជីវិតខ្ញុំ។

**អ្នកសម្ភាសន៍:** តើប្អូនចង់និយាយអ្វីខ្លះទៅកាន់យុវជនផ្សេងទៀតដែលស្ថិតក្នុងស្ថានភាពដូចប្អូនកាលពីមុន?

**វិសាល:** សូមប្អូនៗកុំបោះបង់ក្តីសង្ឃឹម។ កម្មវិធីនេះផ្តល់ឱ្យប្អូនៗនូវជំនាញ និងទំនុកចិត្តក្នុងការផ្លាស់ប្តូរជីវិត។ ប្រសិនបើខ្ញុំអាចធ្វើបាន ប្អូនៗក៏អាចធ្វើបានដែរ។